ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ........ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ២០០៩

# សេចក្តីប្រកាសពត៌មាន

ក្រសួងសុខាភិបាល មានកិត្តិយសសូមជំរាបជូនអស់លោក-លោកស្រី ជាវេជ្ជបណ្ឌិតដែលចេញវេជ្ជបញ្ជា និង ឱសថការីទាំងអស់ ដែលទទួលខុសត្រូវគ្រឹះស្ថានផលិតឱសថ , គ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ , ឱសថស្ថាន-ឱសថស្ថានរង , អាជីវករ និង ប្រជាពលរដ្ឋទាំងអស់ ឱ្យបានជ្រាបថា :

-យោងលិខិតលេខ ០៩០៥ អបស/ឱអបស ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨ របស់ក្រសួងសុខាភិបាល ស្តីពីការបញ្ឈប់នូវការផលិត ការនាំចូល ការចុះបញ្ជីកាឱសថ ការលុបចេញពីបញ្ជីឱសថដែលបានចុះបញ្ជិកា នូវឱសថគ្រុនចាញ់ប្រភេទជាថ្នាំគ្រាប់សំរាប់លេបមួយចំនួន ផលិតដោយជាតិសកម្ម Artemisinin ឬ Artsesunate ឬ Artemether ឬ Dihydroartemisin តែមួយមុខ ដែលបណ្តាលឱ្យមានភាពស៊ាំក្នុងការព្យាបាលជម្ងឺគ្រុនចាញ់ និងដោយពិនិត្យឃើញនៅលើទីផ្សារកម្ពុជាបច្ចុប្បន្ននៅមានចរាចរឱសថគ្រុនចាញ់ខាងលើ ដែលក្រសួងបានហាមឃាត់ ។

អាស្រ័យហេតុនេះ អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងឱសថ ក្រសួងសូមមានវិធានការ ដូចតទៅ :

១-គ្រឹះស្ថានផលិតឱសថ និងគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ ដែលធ្វើប្រតិបត្តិការផលិត នាំចូល ឬចែកចាយឱសថខាងលើ ត្រូវចាត់តាំងការប្រមូលឱសថទាំងនោះ ពីឱសថស្ថាន-ឱសថស្ថានរងនានា ក្នុងព្រះរាជាណាចក្រកម្ពុជា

២-គ្រឹះស្ថានលក់ឱសថទាំងអស់ត្រូវបញ្ឈប់ការតាំងលក់ឱសថខាងលើ ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ

៣-គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវមានវិធានការ ធ្វើការណែនាំ ដល់គ្រប់សាខាគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ-ឱសថស្ថាន-ឱសថស្ថានរង ដូចមានក្នុងចំណុច១ខាងលើ

៤-ក្រសួងនឹងមានវិធានការតឹងរឹងតាមផ្លូវច្បាប់ ចំពោះគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ ឱសថស្ថាន-ឱសថស្ថានរងទាំងឡាយណា ដែលនៅតែបន្តការផលិត ការនាំចូល ឬចែកចាយ និងការតាំងលក់ឱសថខាងលើនេះ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ឱសថការី ជូ-យិនស៊ីម

ចម្លងជូន :
- ក្រសួងព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
- លេខាធិការដ្ឋាន នៃគណៈកម្មការអន្តរក្រសួង និងគណៈកម្មការរាជធានី-ខេត្ត លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- គ្រប់មន្ទីរពេទ្យជាតិ
- គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- គ្រប់ស្ថានីយវិទ្យុ-ទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- គ្រប់សារព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ... ទូរស័ព្ទ: (៨៥៥-២៣) ៨២៦ ០៣៤/៨២៦ ៨៤១ ទូរសារ: (៨៥៥-២៣) ៧២២ ៩៣៣